ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ០៥៦ សព្រក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ផលប៉ះពាល់លើតំបន់ស៊ីវិល និងការគាំពារពលរដ្ឋភៀសសឹក ដោយសារសង្គ្រាមឈ្លានពានទាតទីទឹកដីរបស់រដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ ចាប់ពីម៉ោង៦ល្ងាច ថ្ងៃទី១៨ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីថ្ងៃទី៧ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី១៩ ខែធ្នូនេះ អំពើឈ្លានពានរបស់រដ្ឋាភិបាលក្រុងបាងកក និងយោធាថៃលើកម្ពុជា មិនរើសគោលដៅ ជាពិសេសការផ្លោង និងទម្លាក់គ្រាប់លើតំបន់ស៊ីវិល បានបណ្តាលឱ្យពលរដ្ឋកម្ពុជាស្លាប់១៨នាក់ របួស៧៩នាក់ ខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមានជនភៀសសឹកកើនឡើងជាបន្តបន្ទាប់ ទាំងក្នុងខេត្តជាប់ព្រំដែន និងបណ្តាខេត្តផ្សេងៗទៀត។

**បើគិតពីម៉ោង៦ល្ងាចថ្ងៃទី១៨ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹកថ្ងៃទី១៩ខែធ្នូ ផលប៉ះពាល់មានដូចខាងក្រោម៖**

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានពលរដ្ឋស្លាប់ និងរបួសថ្មីទេ។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖ ខេត្តព្រះវិហារ**មានជនភៀសសឹក ១០.៨៩៦គ្រួសារ ស្មើនឹង ៣៤.៧៣១នាក់ **ឧត្តរមានជ័យ** ១១.៣៧៧គ្រួសារ ស្មើនឹង ៣៨.៣១៩នាក់ **បន្ទាយមានជ័យ** ៥៤.៨៩៥គ្រួសារ ស្មើនឹង ១៨៣.៥៨៧នាក់ **បាត់ដំបង** ១១.៧៨០គ្រួសារ ស្មើនឹង ៤២.២៤៩នាក់ **ពោធិ៍សាត់** ៩០០គ្រួសារ ស្មើនឹង ៣.២២១នាក់ **កោះកុង** ២.៤៥០គ្រួសារ ស្មើនឹង ៨.៧៤៣នាក់ **សៀមរាប** ៤២.១៤៩គ្រួសារ ស្មើនឹង ១៣៣.៣០០នាក់ **កំពត** ៣.៧៧០គ្រួសារ ស្មើនឹង ១១.៥៣៤នាក់ **កំពង់ស្ពឺ** ១.០៧៣គ្រួសារ ស្មើនឹង ៣.៧៨៥នាក់ **កណ្តាល** ២.០១៧គ្រួសារ ស្មើនឹង ៦.៧៧២នាក់ **កំពង់ចាម** ៤.៨២១គ្រួសារ ស្មើនឹង ១៥.២៤២នាក់ **កំពង់ធំ** ៤.៧២២គ្រួសារ ស្មើនឹង ១៤.៣៨៩នាក់ **កែប** ៣២៨គ្រួសារ ស្មើនឹង ១.០៧៣នាក់ **និងខេត្តក្រចេះ** ៤៧៧គ្រួសារ ស្មើនឹង ១.៣៨៣នាក់។ សរុបពីដើមគ្រាមក ជនភៀសសឹកបានកើនដល់ **១៥១.៦៥៥គ្រួសារ ស្មើនឹង ៤៩៨.៣២៨នាក់** ក្នុងនោះស្ត្រីប្រមាណ ២៦ម៉ឺននាក់ និងកុមារប្រមាណជិត ១៦ម៉ឺននាក់។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖ ខូចខាតផ្ទះពលរដ្ឋ៤ខ្នងបន្ថែមទៀត។** ជាបឋម គិតពីថ្ងៃទី៧ ខែធ្នូមក ការខូចខាតសរុបមាន ផ្ទះប្រជាពលរដ្ឋ៧១ខ្នង សាលារៀន១ទីតាំង មណ្ឌលសុខភាព ១ទីតាំង ប្រាសាទបុរាណ១ វត្តអារាម៤ទីតាំង សាលាឆទាន១ទីតាំង កុដិព្រះសង្ឃ១ទីតាំង អគារការិយាល័យ គយ និងរដ្ឋាករចំនួន១អគារ អគារកាស៊ីណូ៤ទីតាំង សណ្ឋាគារ៣ទីតាំង អគារ៤ខ្នង មណ្ឌលកសិកម្មសហគមន៍ ១ទីតាំង ស្ពានថ្ម១ ស្ពានដែក១ ក្បាលស្ពាន១កន្លែង ស្ថានីយ៍ប្រេង១ទីតាំង មធ្យោបាយដឹកជញ្ជូន២៥គ្រឿង ឃ្លាំងរថយន្ត១ ឃ្លាំងទិញដំឡូង១ទីតាំង និងស្ពានបុរាណ១កន្លែង។ ក្រៅពីនេះ សេវាជាមូលដ្ឋាន ដូចជា រដ្ឋបាល សុខាភិបាល និងអប់រំតាមក្រុង ស្រុក ឃុំ-សង្កាត់ ក៏បានផ្អាកស្ទើរទាំងស្រុង ដោយសារតែភាគីថៃបង្កើនការវាយប្រហារមកលើតំបន់ស៊ីវិល ទាំងតាមជើងគោក ជើងទឹក និងជើងអាកាស។

យើងទទូចឱ្យសហគមន៍អន្តរជាតិ ថ្កោលទោស និងមានចំណាត់ការតាមច្បាប់អន្តរជាតិ ដើម្បីឱ្យភាគីថៃបញ្ឈប់សង្គ្រាមឈ្លានពានជាបន្ទាន់ ងាកមកអនុវត្តបទឈប់បាញ់តាមកិច្ចព្រមព្រៀងជាមួយគ្នា ដែល

មានវត្តមានសហរដ្ឋអាមេរិក ចិន និងម៉ាឡេស៊ី ជាអ្នកសម្របសម្រួល និងជាសាក្សី។ ប្រជាពលរដ្ឋកម្ពុជា មិនអាចទទួលយកបានជាដាច់ខាត ចំពោះអំពើឈ្លានពាន ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើយង់ឃ្នងផ្សេងៗ បង្កឡើងដោយរដ្ឋាភិបាលក្រុងបាងកក និងយោធាថៃ។ ក្នុងនាមជាប្រទេសរងគ្រោះ និងធ្លាប់ហែលឆ្លងកាត់សោកនាដកម្មនៃភ្លើងសង្គ្រាម កម្ពុជាបានព្យាយាមដង្ហើយពីក្នុង និងក្រៅប្រទេស ដើម្បីស្វែងរកយុត្តិធម៌ និងឈរលើគោលការណ៍សន្តិសហវិជ្ជមានជានិច្ច។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានមោទនភាព និងកត់ត្រាទុកនូវកម្លាំងមហាសាមគ្គីជាតិ កំពុងមានចលនាកាន់តែសកម្មរឹងមាំខ្ពស់ត្រដែត ដោយកូនខ្មែរគ្រប់រូប នៅគ្រប់ទីកន្លែងទូទាំងពិភពលោក បានវេញស្មារតីជាតិជាធ្លុងមួយ ប្រកៀកស្មាគាំទ្រ និងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**។ មហាកម្លាំងសាមគ្គីនេះ បានផ្តល់ថាមពលដ៏មហិមាជូនដល់កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែន នៃក្រសួងមហាផ្ទៃ ដែលកំពុងកៀកស្មាប្រយុទ្ធការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ប្រកបដោយម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅសមរភូមិ។

ថ្ងៃសុក្រ ១៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥